00704898

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 06 / 2011
ម៉ោង (Time/Heure): 14:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លេខ/No: D14/1/2

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/ក.ស.ច.ស (អ.ប.ជ០៣)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១

---

សាធារណៈ

**ដីកាសម្រេចព្យួរការអនុវត្ត "ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣"**

---

<u>សហព្រះរាជអាជ្ញា</u>
ជា លាង
Andrew CAYLEY

<u>សហចៅក្រមស៊ើបអង្កេត</u>
យូ ប៊ុនឡេង
Siegfried BLUNK

*ដីកាសម្រេចព្យួរការអនុវត្ត*

00704899

**០០៣/០៧-០៩-២០០៩-អវតក/ក.ស.ច.ស (អ.ប.ជ០៣)**

**លេខ/No: D14/1/2**

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" ដែលបានដាក់នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ ("បណ្តឹងឧទ្ធរណ៍")[១]។

១. បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ("ដីកាសម្រេច") ដែលតាមរយៈដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេតបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងរយៈពេលបី (៣) ថ្ងៃ ចាប់តាំងពីថ្ងៃដាក់ដីកាសម្រេចនេះ ធ្វើការផ្សព្វផ្សាយអំពីការដកចេញសេចក្តីប្រកាសព័ត៌មានជាសាធារណៈមួយចំនួន ដែលបានធ្វើឡើងនៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១[២]។

២. នៅក្នុងសេចក្តីជូនដំណឹងស្តីអំពីបណ្តឹងឧទ្ធរណ៍របស់ខ្លួន ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានផ្តល់យោបល់ថា "ដើម្បីកុំឱ្យសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍នេះទៅជាឥតន័យ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា ដីកាសម្រេចបង្គាប់មួយនេះ គួរត្រូវបានព្យួរទុកសិន វៀរលែងតែអង្គបុរេជំនុំជម្រះចេញដីកាបង្គាប់ផ្សេងពីនេះ ឱ្យរង់ចាំសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន"[៣]។

៣. វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនផ្តល់ការបង្ហាញណាមួយស្តីពីថាតើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច ដែលបង្គាប់ឱ្យភាគីណាមួយធ្វើការដកចេញនូវព័ត៌មាន

---

[១] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹង "ដីកាសម្រេចស្តីពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D14/1/1។

[២] ដីកាសម្រេចស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ កថាខណ្ឌ៩។

[៣] សៀវភៅចុះបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ ឯកសារ D14/1។

*ដីកាសម្រេចព្យួរការអនុវត្ត*

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

អាចមានឥទ្ធិពលអ្វីខ្លះ ចំពោះការអនុវត្តដីកាសម្រេចបែបនេះ[៤]។ បើទោះជាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចចាត់របៀប ក្នុងដំណាក់កាលមុនអង្គសេចក្ដី មិនចាំបាច់ត្រូវមានឥទ្ធិពលដើម្បីព្យួរការអនុវត្តសេចក្ដីសម្រេចនេះក៏ដោយ ការព្យួរអាចជាចំណាត់ការសមស្រប នៅក្នុងកាលៈទេសៈដែលការអនុវត្តនូវសេចក្ដីសម្រេចនោះ មុនមានសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍នឹងធ្វើឱ្យសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ទៅជាឥតន័យ។

៤. ដោយហេតុថាវិធានផ្ទៃក្នុង និងច្បាប់ មិនដោះស្រាយលើបញ្ហានេះទេ អង្គបុរេជំនុំជម្រះស្វែងរកការណែនាំនៅក្នុងវិធានស្ដីពីនីតិវិធីដែលបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ ដូចបានណែនាំដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា[៥]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មានការទទួលស្គាល់ថា នៅក្នុងកាលៈទេសៈដែលបទប្បញ្ញត្តិលក្ខន្តិកៈរបស់តុលាការអន្តរជាតិ និងតុលាការអន្តរជាតូបនីយកម្ម មិនបានចែងឱ្យច្បាស់ ឬ អាចឱ្យយល់បានដោយប្រយោល អំពីសមត្ថកិច្ចរបស់តុលាការលើបញ្ហាណាមួយទេនោះ[៦] តុលាការអន្តរជាតិ និងតុលាការអន្តរជាតូបនីយកម្ម មានយុត្តាធិការឥស្សរចិត្តដែលផ្ដល់ឱ្យតុលាការទាំងនេះនូវអំណាច “ដើម្បីសម្រេចលើបញ្ហាមិនសូវសំខាន់ ដែលកើតចេញពីផលវិបាកដោយផ្ទាល់នៃដំណើរការនីតិវិធី ដែល [តុលាការទាំងនេះ] ទទួលបាន ដោយសារតែបញ្ហានោះស្ថិតនៅក្រោមយុត្តាធិការបឋមរបស់ខ្លួន”[៧]។ យុត្តាធិការឥស្សរចិត្ត ត្រូវបានកំណត់និយមន័យថាជា “យុត្តាធិការបន្ទាប់បន្សំ ឬមិនសូវសំខាន់ បន្ថែម

---

[៤] វិធានផ្ទៃក្នុងមានបទប្បញ្ញត្តិស្ដីអំពីការព្យួរការអនុវត្តសេចក្ដីសម្រេច ដែលពាក់ព័ន្ធតែចំពោះការទទួលការពិន័យដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (វិធាន៣៨(៣) នៃវិធានផ្ទៃក្នុង), ដីកាលើការដោះលែងក្នុងដំណាក់កាលនីតិវិធីមុនអង្គសេចក្ដី (វិធាន ៧៧(១៥) នៃវិធានផ្ទៃក្នុង) ឬ បន្ទាប់ពីមានសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (វិធាន ៨២(៦) នៃវិធានផ្ទៃក្នុង)។

[៥] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ មាត្រា១២(១)។ សូមមើលផងដែរវិធាន២ នៃវិធានផ្ទៃក្នុង។

[៦] តុលាការពិសេសសម្រាប់អតីតប្រទេស Lebanon សំណុំរឿងលេខ CH/AC/2010/02 សាលដីកាលើបណ្ដឹងឧទ្ធរណ៍នៃដីការបស់ចៅក្រមអង្គបុរេជំនុំជម្រះសម្រេចលើយុត្តាធិការ និងសិទ្ធប្ដឹង, អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ (“សាលដីកាអង្គជំនុំជម្រះតុលាការកំពូល STL”) កថាខណ្ឌ៤៦ និង៤៨។

[៧] សាលដីកាអង្គជំនុំជម្រះតុលាការកំពូល STL កថាខណ្ឌ៤៥។

ទៅលើយុត្តាធិការបឋម ហើយត្រូវចាត់ទុកថាចាំបាច់ដោយតម្រូវការចាំបាច់ ដើម្បីធានាឱ្យបាននូវកិច្ចការរដ្ឋបាលតុលាការល្អ និងយុត្តិធម៌"[៨]។ ហេតុដូច្នេះ "យុត្តាធិការដែលឥស្សរចិត្តនេះ កើតមានឡើងនៅពេលដែលបញ្ហាណាមួយ ត្រូវបានដាក់នៅចំពោះមុខអង្គភាពណាមួយរបស់តុលាការដែលមានយុត្តាធិការបឋមរបស់ខ្លួនលើបញ្ហានោះ"[៩]។ យុត្តាធិការឥស្សរចិត្តត្រូវបានប្រើប្រាស់ *ក្នុងចំណោមគោលបំណងដទៃទៀត* ដើម្បីសម្រេចឱ្យមានយន្តការបណ្តោះអាសន្ន និងដើម្បីពិចារណាលើបញ្ហានានា ឬ ដើម្បីចេញសាលដីកា *ទៅតាមការផ្តួចផ្តើមខ្លួនឯង (proprio motu)*[១០]។ អង្គបុរេជំនុំជម្រះធ្លាប់ប្រើប្រាស់អំណាចឥស្សរចិត្តរបស់ខ្លួននេះរួចមកហើយ នៅពេលខ្លួនទទួលបានសំណើសុំឱ្យពិចារណាឡើងវិញ[១១] *ក្នុងចំណោមសំណើដទៃទៀត* និងដើម្បីពិនិត្យឡើងវិញ *ទៅតាមការ*

---

[៨] សាលដីកាអង្គជំនុំជម្រះតុលាការកំពូល STL កថាខណ្ឌ៤៥។

[៩] សាលដីកាអង្គជំនុំជម្រះតុលាការកំពូល STL កថាខណ្ឌ៤៥។

[១០] សាលដីកាអង្គជំនុំជម្រះតុលាការកំពូល STL កថាខណ្ឌ៤៦, *ក្នុងចំណោមរឿងផ្សេងទៀត* ស្តីអំពីវិធានការណ៍បណ្តោះអាសន្ន យោងទៅលើ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brima និងអ្នកផ្សេងទៀត,* SCSL-04-16-AR77, សាលដីកាលើញត្តិបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីអនុលោមតាមវិធាន៧៧(ញ) ស្តីពីការដាក់វិធានការណ៍បណ្តោះអាសន្ន និងដីកាសម្រេចអនុលោមតាមវិធាន៧៧(គ)(ii) ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ កថាខណ្ឌ៩។ ECHR, រឿងក្តីMamakutlov និង Askarov តទល់នឹង Turkey, បណ្តឹងលេខ 46827/99 និង 46951/99, សាលក្រម ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ១២៣-១២៤ និងរឿងក្តី *Veerman* ដីកាចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៥៧ នៅក្នុងសេចក្តីសម្រេចរបស់គណៈកម្មការអាជ្ញាកណ្តាលស្តីទ្រព្យសម្បត្តិ សិទ្ធិនិងផលប្រយោជន៍ក្នុងប្រទេសអាល្លឺម៉ង់, ភាគ I (Koblenz, 1958), ទំព័រ១២០, និងអំពីដីកាដែលបានចេញ*ដោយអត្តនោម័ត (proprio motu)*, យោងទៅលើ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Nyiramasuhuko និងអ្នកផ្សេងទៀត*, ITCR-97-21-T, ITCR-97-29-T, ITCR-96-15-T, ICTR-96-8-T, សេចក្តីសម្រេចលើការចោទប្រកាន់របស់រដ្ឋអាជ្ញាទាក់ទងនឹងការប្រមាថ, សុខដុមកម្មនៃវិធានការណ៍ការពារសាក្សី និងការព្រមានចំពោះក្រុមរដ្ឋអាជ្ញា ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០១ កថាខណ្ឌ១៩ (រៀបរាប់ឡើងវិញនូវដីកាសម្រេច*ដោយអត្តនោម័ត*លើការការពារសាក្សីដែលបានស្នើ)។

[១១] ទោះបីជាសំណើសុំឱ្យមានការពិចារណាឡើងវិញត្រូវបានដាក់ទៅអង្គបុរេជំនុំជម្រះបានបរាជ័យក៏ដោយ ក៏អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា អង្គបុរេជំនុំជម្រះមានអំណាចឥស្សរចិត្តដើម្បីពិចារណាលើសេចក្តីសម្រេចពីមុន។ សូមមើល *ក្នុងចំណោមរឿងផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៣), សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ C22/I/68, កថាខណ្ឌ២៥, យោងទៅលើសេចក្តីសម្រេចក្នុង *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Galic*, IT-98-29-A, "សាលដីកាលើសំណើសុំរបស់មេធាវីការពារក្តី សុំឱ្យមានការពិចារណាឡើងវិញ", អង្គជំនុំជម្រះតុលាការកំពូល, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ ទំព័រ២។

*ផ្តួចផ្តើមរបស់ខ្លួន* នូវកំហុសនីតិវិធីនានារបស់សហចៅក្រមស៊ើបអង្កេត ដែលមិនបានលើកឡើងដោយមេធាវីការពារក្តី[១២]។

៥. យ៉ាងណាមិញ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ព័ត៌មានដែលសហចៅក្រមស៊ើបអង្កេតស្នើឱ្យសហព្រះរាជអាជ្ញាអន្តរជាតិធ្វើការដកចេញនោះ ត្រូវបានដកស្រង់នៅក្នុងដីកាសម្រេចចេញដោយសហចៅក្រមស៊ើបអង្កេត ដែលខ្លួនបានចាត់ថ្នាក់ឯកសារនោះថាសាធារណៈ[១៣]។ ហេតុដូច្នេះ ព័ត៌មាននៅតែបើកចំហដល់សាធារណជន បើទោះជាព័ត៌មាននោះត្រូវបាន "ដកចេញ" ដោយសហព្រះរាជអាជ្ញាក៏ដោយ។ ហេតុដូច្នេះ ការអនុវត្តដីកាសម្រេចដោយសហព្រះរាជអាជ្ញាដែលរង់ចាំការសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន នឹងមិនមានឥទ្ធិពលលើការរក្សាភាពសម្ងាត់នៃព័ត៌មាននេះទេ។ យ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា សិទ្ធិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការប្តឹងឧទ្ធរណ៍នៅចំពោះមុខខ្លួននៅក្នុងសំណុំរឿងនាពេលនេះ នឹងមានលក្ខណៈជាទ្រឹស្តី ប្រសិនបើសហព្រះរាជអាជ្ញាអន្តរជាតិត្រូវតែអនុវត្តដីកាសម្រេច មុនពេលមានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ ដោយបានទទួលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច និងដោយបានពិចារណាលើការពន្យារពេលដ៏ខ្លីមួយ សម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការអនុវត្តដីកាសម្រេចនោះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាគឺជាផលប្រយោជន៍នៃយុត្តិធម៌ ដែលអង្គបុរេជំនុំជម្រះអនុវត្តនូវយុត្តាធិការឥស្សរចិត្តរបស់ខ្លួន ដើម្បីព្យួរ *តាមការផ្តួចផ្តើមរបស់ខ្លួន* នូវការអនុវត្តដីកាសម្រេច ដោយរង់ចាំការសម្រេចចុងក្រោយលើបណ្តឹងឧទ្ធរណ៍។

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C. * C.E.T.C.

---

[១២] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០១, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ៩-១២។

[១៣] ដីកា កថាខណ្ឌ២ និង៣។

00704903

**០០៣/០៧-០៩-២០០៩-អវតក/ក.ស.ច.ស (អ.ប.ជ០៣)**

**លេខ/No: D14/1/2**

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ**

**បង្គាប់** ថា ការអនុវត្តដីកាសម្រេចត្រូវបានព្យួរ រហូតមានការសម្រេចចុងក្រោយលើបណ្ដឹងឧទ្ធរណ៍។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១

ប្រធាន អង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

**ប្រាក់ គឹមសាន**